ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល
លេខៈ ០៥៤/២៣ អអរ

# សេចក្តីប្រកាសព័ត៌មាន
# លទ្ធផលនៃសន្និសីទសារព័ត៌មានស្តីពី "ភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តកំពង់ធំ"

ព្រឹកថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៣ អង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលបានរៀបចំសន្និសីទសារព័ត៌មាន ស្តីពី **«ភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តកំពង់ធំ»** ដែលមានវាគ្មិនចូលរួមគឺ៖

- **ឯកឧត្តម ងួន រតនៈ អភិបាល នៃគណៈអភិបាលខេត្តកំពង់ធំ**
- **មន្ទីរអង្គភាពជំនាញជុំវិញរដ្ឋបាលខេត្តកំពង់ធំ**

ខ្លឹមសារនៃសន្និសីទសារព័ត៌មាន មានគោលបំណងពន្យល់ និងផ្សព្វផ្សាយដល់សាធារណជនឱ្យបានជ្រាបច្បាស់អំពី យន្តការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងភាពជោគជ័យដែលរដ្ឋបាលខេត្តកំពង់ធំ ខិតខំប្រឹងប្រែងអនុវត្ត ព្រមទាំងសម្រេចបានសមិទ្ធផលវិជ្ជមាន ក្រោមការដឹកនាំដ៏ប៉ិនប្រសប់ប្រកបដោយថាមពលរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។**

## I. ស្ថានភាពទូទៅ

ខេត្តកំពង់ធំ មានផ្ទៃដីសរុប ១៥.០៦១គីឡូម៉ែត្រការេ មានប្រជាពលរដ្ឋសរុប ៨៤៣.៦៤៤នាក់។ ទំហំសេដ្ឋកិច្ចរបស់ខេត្តមានប្រមាណ ៤% នៃសេដ្ឋកិច្ចជាតិទាំងមូល ដោយចំណូលជាមធ្យមរបស់ប្រជាពលរដ្ឋម្នាក់ បានកើនដល់ ១.០១៣ដុល្លាអាមេរិក អត្រាភាពក្រីក្របានថយចុះពី ២២,៧១% ក្នុងឆ្នាំ២០១៨ មកត្រឹម ១៣,៣៥% ក្នុងឆ្នាំ២០២២។

## II. សមិទ្ធផលការងារ

ក្នុងរយៈពេល ៥ឆ្នាំកន្លងមកនេះ រដ្ឋបាលខេត្តកំពង់ធំ សម្រេចបាននូវសមិទ្ធផលការងារសំខាន់ៗ រួមមាន៖

- **វិស័យគាំពារសង្គម៖** ដោយអនុវត្តតាមគោលនយោបាយគាំពារសង្គមរបស់រាជរដ្ឋាភិបាល រដ្ឋបាលខេត្តបានអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់សរុបអស់ចំនួន ២១៧.២៧៣.៣៦៨.០០០រៀល ដោយក្នុងនោះ គ្រួសារក្រីក្រងាយរងផលប៉ះពាល់ដោយជំងឺកូវីដ-១៩ ទទួលបានចំនួន ៤៣.២៩២គ្រួសារ ចំណាយថវិកាអស់ ២១០.៩៩១.៤៤៨.០០០រៀល, ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ ចំនួន ១០.២៣៩នាក់ ស្មើនឹងថវិកា ៣.៩៧២.៣២០.០០០រៀល, គ្រួសារងាយរងហានិភ័យដោយសារសម្ពាធអតិផរណា និងគ្រោះទឹកជំនន់ ចំនួន ១៨.៩៤៥គ្រួសារ ចំណាយថវិកាអស់ ២.៦៨៨.៥២៤.៧០០រៀល និងឧបត្ថម្ភបន្ថែមដល់កម្មករនយោជិតជាស្ត្រីពេលសម្រាលកូនចំនួន ៥.៧៧៤នាក់ ចំណាយថវិកា ២.៣០៩.៦០០.០០០រៀល។
- **ការងារសន្តិសុខ សណ្តាប់ធ្នាប់សង្គម និងការផ្តល់សេវាសាធារណៈ៖** រដ្ឋបាលខេត្តបានខិតខំបំផុសចលនាឱ្យមានការចូលរួមពីមូលដ្ឋានទាំងអាជ្ញាធរ និងប្រជាពលរដ្ឋ ដើម្បីរួមគ្នារក្សាការពារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមបានល្អ កាត់បន្ថយបទល្មើស និងល្បែងស៊ីសងគ្រប់ប្រភេទ ទទួលបានជ័យលាភីល្អប្រសើរ ក្នុងការប្រលងប្រណាំងភូមិ-ឃុំ មានសុវត្ថិភាព។ ជាមួយគ្នានេះ រដ្ឋបាលខេត្តបានខិតខំជំរុញនូវការអនុវត្តយន្តការច្រកចេញចូលតែមួយដោយបានពង្រីកនូវការិយាល័យច្រកចេញចូលតែមួយដល់មូលដ្ឋានឃុំ សង្កាត់ផ្ទាល់ ជាលទ្ធផលបានផ្តល់សេវាសរុបចំនួន ១៩៨.៦៥៨សេវា ស្មើនឹងថវិកាចំនួន ៨.៥៣៧.១៣០.៤៥៧រៀល។
- **វិស័យកសិកម្ម៖** ដោយជាវិស័យចម្បងរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចខេត្តទាំងមូល ខេត្តមានផ្ទៃដីដាំដុះស្រូវសរុបចំនួន ២៥៣.៣០០ហ.ត ទិន្នផលជាមធ្យម ៤តោន/ហិកតា, ផ្ទៃដីដាំកៅស៊ូក្រុមហ៊ុន សរុបចំនួន ៥៣.៩៨៤ហ.ត, កៅស៊ូគ្រួសារ ៨.៥៦៣,២១ហ.ត ក្រៅពីនោះ រួមមានដំណាំរួមផ្សំមួយចំនួនទៀតដូចជា ស្វាយចន្ទី ស្វាយកែវរមៀត ដំឡូងមី តាដែនជាដើម។ ដើម្បីបង្កើនគុណភាពទិន្នផលដំណាំកសិកម្មខាងលើ ខេត្តបានបង្កើតឱ្យមាន ឡសម្ងួតស្រូវ៣០ ម៉ាស៊ីនសម្ងួត២៣កន្លែង ក៏ដូចជារោងចក្រកែច្នៃ ៤កន្លែង។ ជាមួយគ្នានេះ ដើម្បីជាការជំរុញនូវការរីកចម្រើនទៅលើវិស័យកសិកម្មនេះ ខេត្តបានប្រឹងប្រែងសាងសង់ ជួសជុល និងកែលម្អប្រព័ន្ធធារាសាស្ត្រជាប្រចាំ។
- **វិស័យទេសចរណ៍៖** ទូទាំងខេត្តមានរមណីយដ្ឋានទេសចរណ៍ សហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍សំខាន់ៗជាច្រើនកន្លែង សម្រាប់ទាក់ទាញភ្ញៀវទេសចរបានយ៉ាងច្រើន ប៉ុន្តែ

ដោយបញ្ហាជំងឺកូវីដ-១៩ បណ្តាលឱ្យភ្ញៀវទេសចរណ៍បានធ្លាក់ចុះយ៉ាងគំហុក យ៉ាងណាមិញ ក្រោយពីការបើកប្រទេសឱ្យដំណើរឡើងវិញ វិស័យទេសចរណ៍ក្នុងខេត្តកំពង់ធំបាន និងកំពុងមកភាពល្អប្រសើរឡើងវិញ ដោយក្នុងឆ្នាំ២០២២នេះ ភ្ញៀវទេសចរណ៍ចំនួន ២៩៤.៤១០នាក់ ធៀបឆ្នាំ២០២១ មានការកើនឡើង ៣៥៤,៩៧% ។

- **ការងារអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តៈ** ខេត្តមានផ្លូវជាតិសំខាន់ចំនួន ០៥ ឆ្លងកាត់គឺ ផ្លូវជាតិលេខ៦ ផ្លូវជាតិលេខ៦២ ផ្លូវជាតិលេខ៧១ ផ្លូវជាតិលេខ៥០C ផ្លូវជាតិលេខ៦០B និងកំណាត់ផ្លូវខេត្តក្រាលកៅស៊ូមានចំនួន ១២ខ្សែ រួមទាំងផ្លូវលំជនបទចំនួន ១.១០៨ខ្សែ។ ជាមួយគ្នានេះ រដ្ឋបាលខេត្ត បាននិងកំពុងយកចិត្តទុកដាក់ក្នុងការពង្រីកនូវការផ្គត់ផ្គង់អគ្គិសនី និងទឹកស្អាតជូនប្រជាពលរដ្ឋ ជាពិសេសនៅតាមទីជនបទ និងតំបន់ដាច់ស្រយាល ដោយជាក់ស្តែង អត្រាភូមិដែលមានអគ្គិសនីប្រើប្រាស់ប្រមាណ ៩៧.៩១% ក្នុងចំណោម ៧៦៧ភូមិ និងបានដាក់បំពង់ទឹកស្អាតបានចំនួន ៨៧៣.០០០ម ក្នុងភូមិចំនួន ២៣២ភូមិ ស្មើនឹង ៧៤% នៃភូមិក្នុងតំបន់សេវាកម្ម ៣១៨ភូមិ។

## III. ទិសដៅការងារបន្ត

រដ្ឋបាលខេត្តកំពង់ធំ បានដាក់ចេញនូវទិសដៅការងារសំខាន់ៗ ដើម្បីបន្តអភិវឌ្ឍន៍ខេត្ត ដែលរួមមានៈ

- បន្តពង្រឹងការផ្តល់សេវាសាធារណៈ តាមរយៈយន្តការច្រកចេញចូលតែមួយ និងបន្តរៀបចំយន្តការច្រកចេញចូលតែមួយឱ្យបានគ្រប់ឃុំ/សង្កាត់
- ជួយគាំទ្រ និងបង្កើនសមត្ថភាពដល់រដ្ឋបាលក្រុង ស្រុក លើការងារគ្រប់គ្រងធនធាន មនុស្សនៃរចនាសម្ព័ន្ធរដ្ឋបាលក្រុង/ស្រុក ដែលទើបធ្វើសមាហរណកម្មថ្មី ឆ្នាំ២០២០
- ណែនាំ និងពិនិត្យសុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ សោភ័ណភាព គុណភាព សំណង់ និងផលប៉ះពាល់ផ្សេងៗ ក្នុងការជួសជុល និងកែសម្រួលបណ្តាសំណង់សាធារណៈ និងសំណង់បេតិកភ័ណ្ឌ
- បន្តជំរុញការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោកឱ្យអស់ពីលទ្ធភាព ស្របតាមគោលការណ៍របស់គណៈបញ្ជាការ ដឹកនាំ បញ្ជា ត្រួតពិនិត្យការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោកថ្នាក់ខេត្ត ឱ្យមានប្រសិទ្ធភាព សំដៅកាត់បន្ថយគ្រោះថ្នាក់ចរាចរឲ្យស្ថិតនៅកំរិតទាប
- បន្តជំរុញការងារបង្ក្រាបសកម្មភាពក្មេងទំនើង និងបទល្មើសគ្រឿងញៀន
- ជំរុញ និងពិនិត្យលទ្ធភាពនៃការរៀបចំទីលានទុកដាក់សម្រាម និងធ្វើអាងប្រព្រឹត្តិកម្មសំណល់រាវតាមលក្ខណៈបច្ចេកទេសឲ្យបានគ្រប់ក្រុង/ស្រុក។

## IV. សម្គាល់

ដោយអនុវត្តស្របតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ខេត្តទទួលបាននូវការអភិវឌ្ឍ និងរីកចម្រើនស្ទើរគ្រប់វិស័យ រួមមានទាំងការអភិវឌ្ឍធនធានមនុស្ស ការរីកចម្រើនហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ។ ជាមួយគ្នានេះ ការថែរក្សាអនាម័យក៏ត្រូវបានលើកកម្ពស់ ដោយខេត្តបានរៀបចំឱ្យមានទីលានចាក់សម្រាមនៅតាមបណ្តាក្រុង ស្រុក ព្រមទាំងបានកំពុងរៀបចំប្រព័ន្ធលូទឹកកខ្វក់ ទឹកភ្លៀង និងអាងប្រព្រឹត្តកម្មទឹកកខ្វក់ ក្នុងការរួមចំណែកលើកកម្ពស់ការរស់នៅរបស់ប្រជាពលរដ្ឋ ដោយសម្រេចបានលទ្ធផលបាន ៩៤,២០%។ បន្ថែមពីនោះ រដ្ឋបាលខេត្តបានអនុវត្តតាមអនុសាសន៍ណែនាំ និងបទបញ្ជាដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ដោយបានកែសម្រួលព្រំប្រទល់ដីពីតំបន់២ មកតំបន់១ ជូនប្រជាពលរដ្ឋចំនួន ១០.៨០៣គ្រួសារ ស្មើនឹង ១៧.៣៣៩ហ.ត, កែសម្រួលផ្ទៃដីពីតំបន់៣ មកតំបន់២ ជូនប្រជាពលរដ្ឋចំនួន ៨.៦៦១គ្រួសារ ស្មើនឹង ៣៤.១៥៩ហ.ត និងបានស្នើសុំកាត់ឆ្វៀលដីចេញគម្របព្រៃឈើ២០០២ និងដីសហគមន៍ ផ្ទៃដីទំហំ ១៦១.៤៣៩,១៤ហ.ត ស្មើនឹង ៤៦.៥៣៣គ្រួសារ ព្រមទាំងបានស្នើសុំកាត់ឆ្វៀលដីតំបន់ការពារបរិស្ថាន ក្នុងខេត្តទំហំ ៦២.៨៨៣ហ.ត ស្មើនឹង ១៥.៧២៩គ្រួសារ៕ Den

ថ្ងៃអង្គារ ៩រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៣